# នួន ជា ភ្លេចភ្លាំង ហើយ ខៀវ សំផន បដិសេធមិនផ្តល់សក្ខីកម្ម : សវនាការក្នុងករណី00២បន្ត

*ថ្ងៃទី១២ ខែមករា ឆ្នាំ២០១២*

***ដោយ វ៉េនឌល ឌីហ្វាលកូ***

*ប្រែសម្រួលដោយ ផា ផល្លា*

*“ខ្ញុំមិនចាំទេ” --នួន ជា*

*នៅថ្ងៃព្រហស្បតិ៍ ទី១២ ខែមករា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តដំណើរការសវនាការលើភស្តុតាងទាក់ទងទៅនឹងប្រវត្តិកំណារកំណើតនៃចលនាខ្មែរក្រហម ។ កម្មវិធីនៅពេលព្រឹក ជាពេលវេលាសម្រាប់ជនជាប់ចោទ នួន ជា ធ្វើសក្ខីកម្ម ហើយ ខៀវ សំផន នឹងធ្វើសក្ខីកម្មរបស់ខ្លួននៅពេលរសៀល ។ ចំណែកឯ អៀង សារី ធ្លាប់បានជម្រាបមកអង្គជំនុំជម្រះរួចមកហើយថា គាត់រក្សាសិទ្ធិនៅស្ងៀម និងមិនធ្វើសក្ខីកម្មនៅចំពោះមុខអង្គសវនាការនោះទេ ។*

## ផលលំបាកក្នុងការបកប្រែ

*មុននឹងកិច្ចដំណើរការចាប់ផ្តើមនៅថ្ងៃនេះ ប្រធាន និល ណុន បានរំឭកទៅគ្រប់ភាគីទាំងអស់ជាពិសេសមេធាវីប្រឹក្សាអន្តរជាតិថា ត្រូវមានការប្រុងប្រយ័ត្នក្នុងការអានឈ្មោះព្រោះបើសិនជាអានខុស អ្នកបកប្រែក៏មានការលំបាកក្នុងការបកប្រែដែរ ។ លោកចៅក្រម បានណែនាំឲ្យអានលេខ* “ERN” *រាល់ឯកសារទាំងអស់ដែលបានយកមកធ្វើជាឯកសារយោង ។ ក្រោយពីចៅក្រមនិយាយចប់ លោក អាង ឧត្តម មេធាវីការពារក្តីរបស់ អៀង សារី បានក្រោកឈរនិងបានបង្ហាញពីក្តីបារម្ភរបស់គាត់ ដោយបញ្ជាក់ថា កាលពីម្សិលមិញ ព្រះរាជអាជ្ញារងអន្តរជាតិលោក ដា លីសាក់ បានអានឈ្មោះខុស ដែលធ្វើឲ្យមានការភាន់ច្រឡំ ដូច្នេះលោកស្នើឲ្យមេធាវីជាតិទាំងអស់គួរតែហាត់អានឈ្មោះនៅក្នុងបន្ទប់ធ្វើការរបស់ខ្លួនជាមុនសិន មុននឹងយកឈ្មោះនោះទៅអាននៅចំពោះមុខអង្គសវនាការ ។*

## ព្រះរាជអាជ្ញាពង្រាងសំណួរសម្រាប់សួរ នួន ជា

*ក្នុងដំណើរការសវនាការនៅថ្ងៃនេះ ចៅក្រម និល ណុន បានសួរទៅព្រះរាជអាជ្ញាថា តើត្រូវការពេលវេលាប៉ុន្មានទៀតដើម្បីចោទសួរទៅជនជាប់ចោទ នួន ជា ។ ព្រះរាជអាជ្ញាបានជូនដំណឹងទៅអង្គជំនុំជម្រះថានឹងបញ្ចប់ការសាកសួរលើជនជាប់ចោទ នួន ជា ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ បន្ទាប់មកលោក ដា លីសាក់ បានរៀបរាប់ពីប្រធានបទមួយចំនួនដែលនៅសល់មានដូចជា :*

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

- *ការពិភាក្សាអំពីអង្គភាពការពារសម្ងាត់*
- *សមាជបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៦៣ និងហេតុការណ៍មួយចំនួនមុននឹងកើតរដ្ឋប្រហារ ខែមិនា ឆ្នាំ១៩៧០ ។*
- *សម័យកាលអំឡុងពីឆ្នាំ១៩៧០ ដល់ខែមេសា ឆ្នាំ១៩៧៥ និង*
- *ការបង្កើតសហករណ៍ និងការផ្លាស់ប្តូរលំនៅដ្ឋានប្រជាជននៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហមពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៥ ។*

*ព្រះរាជអាជ្ញាបានបញ្ជាក់ថា ដោយសារសំណួរនៅមានច្រើន «វាអាស្រ័យលើជនជាប់ចោទផ្ទាល់ថាតើជនជាប់ចោទឆ្លើយចំសំណួរឬអត់?» ។*

*មុននឹងការសាកសួរចាប់ផ្តើម នួន ជា បានក្រោកឈរឡើង ហើយបញ្ជាក់ទៀតថា គាត់នឹងជំទាស់រាល់ឯកសារថតចម្លងទាំងអស់ ។ នួន ជា បានបញ្ជាក់ពីបំណងរបស់ខ្លួនថា ដើម្បី«បញ្ជាក់ម្តងទៀតថា ខ្ញុំមិនអាចទទួលយកឯកសារថតចម្លងជាមូលដ្ឋានក្នុងការចោទសួរមកលើខ្ញុំទេ ហើយក្នុងករណីនេះ ខ្ញុំសូមអនុវត្តសិទ្ធិរបស់ខ្ញុំក្នុងការមិនឆ្លើយតបទៅនឹងសំណួរដែលទាក់ទងទៅនឹងឯកសារនោះ» ។*

*ចៅក្រម និល ណុន បានថ្លែងអំណរគុណដល់ នួន ជា ដែលបានបញ្ជាក់ឲ្យច្បាស់ត្រង់ចំណុចនេះ ជាមួយគ្នានោះដែរ ចៅក្រមបានរំឭកទៅ នួន ជា វិញថា អង្គជំនុំជម្រះបាន កំណត់ពីភាពត្រឹមត្រូវរបស់ឯកសារទាំងនោះហើយ ហើយអង្គជំនុំជម្រះបានបញ្ជាក់ទៅ នួន ជា ទៀតថា បើ នួន ជា មិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះនឹងសន្មត់ថា នួន ជា កំពុងអនុវត្តសិទ្ធិនៅស្ងៀមរបស់ខ្លួន ។*

*ក្រោយមក នួន ជា បានប្រកាសថា គាត់«សូមឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យព្រះរាជអាជ្ញាជូនឯកសារមកគាត់ឲ្យទាន់ពេលវេលាបើសិនជាចង់បង្ហាញឯកសារណាមួយ ។ ធ្វើដូច្នេះ គាត់អាចនឹងពិនិត្យមើលឯកសារនោះឲ្យបានម៉ត់ចត់ ហើយគាត់នឹងអាចដាក់សំណើផ្សេងៗទាក់ទងនឹងឯកសារនោះនៅចំពោះមុខតុលាការផង» ។ បើសិនជាឯកសារនោះវែងពេក ខ្ញុំស្នើថា ព្រះរាជអាជ្ញាដៅតែចំណុចសំខាន់ៗបានហើយ ។ សម្រាប់ពេលនេះ ខ្ញុំមានការលំបាកពិនិត្យមើលឯកសារដែលបានដាក់នៅចំពោះមុខតុលាការនេះណាស់ ព្រោះខ្ញុំមិនមានពេលគ្រប់គ្រាន់» ។ អង្គជំនុំជម្រះឆ្លើយតបដោយអនុញ្ញាតឲ្យព្រះរាជអាជ្ញាសួរសំណួរបន្តទៀត ។*

## ***ការបន្តសួរទៅកាន់ នួន ជា អំពីអង្គភាពការពារសម្ងាត់***

*សំណួរទីមួយរបស់ព្រះរាជអាជ្ញាគឺទាក់ទងទៅនឹងទម្រង់ក្នុងការបំបាត់សត្រូវ ។ ត្រង់ចំណុចនេះ នួន ជា បានបញ្ជាក់ថា មានគិញជាច្រើនព្យាយាមរុកគួនបក្សកុម្មុយនីស្តកម្ពុជាជាប់រហូត ក្នុងគោល*

បំណង ធ្វើការបំផ្លាញដល់បដិវត្តន៍ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាបានឆ្លើយតបទៅវិញដោយបង្កើតជាកងការពារសម្ងាត់ដើម្បីត្រួតពិនិត្យមើលបុគ្គលណាដែលប្រព្រឹត្ត «អំពើសង្ស័យ» ។ កងអង្គភាពនេះត្រូវបានផ្តល់សិទ្ធិឲ្យស៊ើបអង្កេតនិងចាប់ខ្លួនជនក្បត់ ។

នៅពេលសួរថា តើមានរឿងអ្វីកើតឡើងចំពោះនរណាដែលត្រូវបានកំណត់ថាជាគិញដែលចង់បំផ្លាញបក្សនោះ? នួន ជា បានឆ្លើយថា «បើសិនជាមានរឿងបែបនេះបក្សត្រូវចំណាយពេលវេលាស៊ើបអង្កេតអ្នកនោះសិន ។ វាអាចចំណាយពេលមួយឆ្នាំ ទៅពីរឆ្នាំ ឬលើសពីនេះ ហើយក្រោយមកអ្នកនោះនឹងត្រូវចាប់ខ្លួន រួចបញ្ជូនទៅមន្ទីរស-២១ ដែលនៅទីនោះគិញនោះត្រូវបានឲ្យសរសេរនូវចម្លើយសារភាពព្រមទាំងឲ្យធ្វើសក្ខីកម្ម» ។

ព្រះរាជអាជ្ញាមានការពេញចិត្តទៅនឹងអ្វីដែល នួន ជា បកស្រាយពីការបញ្ជូនសត្រូវទៅមន្ទីរស-២១ ។ ព្រះរាជអាជ្ញាបានបន្តសួរសំណួរទាក់ទងទៅនឹងហេតុការណ៍មុនឆ្នាំ១៩៧៥ និងការបង្កើតចលនាខ្មែរក្រហមដំបូងក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ។ ព្រះរាជអាជ្ញាសួរ តើមន្ទីរសន្តិសុខដំបូងគេបង្កើតនៅពេលណា មុនឆ្នាំ១៩៧៥? នួន ជា ឆ្លើយភ្លាមថា «មិនដឹងទេ» ។ គាត់បានបញ្ជាក់ទៀតថា គាត់មិនដឹងអំពីមន្ទីរសន្តិសុខដែលមានឈ្មោះថា ស-៣៩ ឬ ម-១៣ ទេ ព្រោះនៅពេលនោះ កម្មាភិបាលម្នាក់ៗត្រូវបានណែនាំឲ្យធ្វើតែកិច្ចការរបស់ខ្លួនប៉ុណ្ណោះ ហើយកិច្ចការរបស់គាត់ទាក់ទងទៅនឹងការអប់រំប៉ុណ្ណោះ ដូច្នេះគាត់មិនដឹងពីបញ្ហាមន្ទីរសន្តិសុខទេ ។

## សមាជបក្សកុម្មុយនីស្តកម្ពុជាលើកទីពីរក្នុងឆ្នាំ១៩៦៣

ព្រះរាជអាជ្ញាបានប្តូរសំណួរសួរអំពីប្រធានបទដែលទាក់ទងទៅនឹងសមាជបក្ស ក្នុងឆ្នាំ១៩៦៣វិញ ។ ពេលនោះ នួន ជា បានរំឭកថា សមាជលើកទីពីរធ្វើឡើងនៅក្នុងផ្ទះមួយដោយមានការចូលរួមពីសមាជិកច្រើន ដូចសមាជកាលពីឆ្នាំ១៩៦០ដែរ ដើម្បីចូលជាសមាជិកបក្សនៅពេលនោះ នួន ជា បាននិយាយថា បេក្ខជនត្រូវតែមាន«តម្លៃបដិវត្តន៍» និង«គាំទ្រដោយមហាជន» ទើបអាចចូលបដិវត្តន៍បាន ។ នួន ជា បានបន្តទៀតថា ភាពចាស់ទុំក៏ជាកត្តាមួយដែរ តែនេះជាជំហានទីពីរទេ ។ នៅពេលសួរថា តើក្រុមប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាដែលហៅថា«ក្រុមប្រជាជន»មិនពេញចិត្តនឹងការដឹកនាំរបស់ នួន ជា កាលពីសមាជឆ្នាំ១៩៦៣នោះ ដែលធ្វើឲ្យក្រុមនោះលើក ប៉ុល ពត ឲ្យចូលមកកាន់តំណែងលើគាត់ឬយ៉ាងណា? នួន ជា បានឆ្លើយថា សមាជនោះសម្រេចថា ប៉ុល ពត មានចរិតបដិវត្តន៍ល្អច្រើន ដែលជាហេតុធ្វើឲ្យគាត់ត្រូវបានបក្សជ្រើសរើសជាលេខាបក្ស ។

ជាមួយគ្នានោះដែរ មានការយល់ច្រឡំខ្លះទាក់ទងទៅនឹងការប្រើប្រាស់ពាក្យរបស់ព្រះរាជអាជ្ញាអំពីពាក្យ «ក្រុមប្រជាជន» ក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា បានកែតម្រូវព្រះរាជអាជ្ញាថា

ក្រុមនេះ គឺជាក្រុមមួយផ្សេងទៀតដែលធ្វើសកម្មភាពទូទៅ តែមិនមែនជាក្រុមបក្សកុម្មុយនីស្តកម្ពុជាទេ។ នួន ជា បានជំទាស់ថា កាលនោះមិនមានក្រុមប្រជាជននេះចូលរួមក្នុងសមាជឆ្នាំ១៩៦៣ទេ ព្រោះក្រុមនេះជា"ក្រុមផ្សេង"ពីបក្សកុម្មុយនីស្តកម្ពុជា ហើយក៏មិនអាចលាយគ្នាបានទេ។

នៅពេលសួរពីគណៈអចិន្ត្រៃយ៍ថ្មីដែលត្រូវបានជ្រើសរើសកាលពីសមាជឆ្នាំ១៩៦៣ នួន ជា បានសង្កេតឃើញថា ពាក្យ "តែងតាំង" និង "ជ្រើសតាំង" គឺជាភាពខុសគ្នា ហើយបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជាជាទូទៅបញ្ចូលនរណាម្នាក់ជាសមាជិកដោយបីវិធី ៖ ជ្រើសរើស តែងតាំង និងការជ្រើសរើសជាសម្ងាត់។ នួន ជា បានបន្តទៀតថា នៅឯសមាជនោះ ប៉ុល ពត ត្រូវបាន"តែងតាំង" ជាលេខាបក្ស ហើយគាត់នៅតែជាអនុលេខាដដែល ចំណែកឯ អៀង សារី នឹង សោ ភឹម ត្រូវបានតែងតាំងជាគណៈអចិន្ត្រៃយ៍។ នួន ជា បានបន្ថែមថា តាម៉ុក និង សុន សេន ក៏ត្រូវបានតែងតាំងជាសមាជិករបស់គណៈអចិន្ត្រៃយ៍ជាមួយនឹងកម្មាភិបាលផ្សេងទៀតដែលគាត់មិនចាំឈ្មោះ។ នួន ជា បានឲ្យដឹងទៀតថា កាលពីសមាជបក្សឆ្នាំ១៩៦៣នោះ ចលនាខ្មែរក្រហមត្រូវបានប្តូរឈ្មោះជាផ្លូវការមកពី"បក្សពលករ" មក"បក្សកុម្មុយនីស្តកម្ពុជា"វិញ។

**ហេតុការណ៍ក្នុងអំឡុងពេលពីសមាជឆ្នាំ១៩៦៣រហូតដល់រដ្ឋប្រហារ លន់ នល់ ឆ្នាំ១៩៧០**

ត្រលប់ទៅរកព្រឹត្តិការណ៍មុនឆ្នាំ១៩៧០វិញ ព្រះរាជអាជ្ញាបានសួរទៅ នួន ជា ថាតើ ខៀវ សំផន សរសេរត្រូវទេនៅក្នុងសៀវភៅរបស់គាត់ដែលបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាបានធ្វើដំណើរទៅភូមិភាគឥសានដើម្បីរៀបចំសមាជឆ្នាំ១៩៦៣នោះ។ នួន ជា បានឆ្លើយថា គាត់មិនបានអានសៀវភៅនោះទេ ហើយគាត់មិនបានផ្តល់យោបល់ទាក់ទងទៅនឹងសៀវភៅនោះទេ តែគាត់បានបញ្ជាក់ថា មេដឹកនាំឈរជើងនៅតាមព្រំដែនកម្ពុជាវៀតណាមប៉ែកខាងកើត។ នួន ជា បានបដិសេធថា គាត់មិនមែនជាអ្នកនាំផ្លូវ អៀង សារី និង សុន សេន ទៅតំបន់នោះទេ ហើយគាត់ក៏មិនបានរស់នៅជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទេនៅពេលនោះ។ គាត់បានបញ្ជាក់ទៀតថា គាត់ធ្លាប់ជួប ប៉ុល ពត ម្តងប៉ុណ្ណោះក្នុងអំឡុងពេលនោះ។ គាត់បាននិយាយថា ប៉ុល ពត "មិនចូលចិត្តរស់នៅជិតវៀតណាមទេ" ព្រោះ ប៉ុល ពត "មិនចង់ឲ្យមានការភាន់ច្រឡំ"អំពីការបែងចែករវាងក្រុមទាំងពីរនេះទេ ហើយ ប៉ុល ពត ក៏គោរពអំពីទឹកដីរបស់វៀតណាមដែរ។

ក្រោយពីសួរសំណួរផ្សេងទៀត នួន ជា បានបញ្ជាក់ថា មុនឆ្នាំ១៩៦៦ ប៉ុល ពត, អៀង សារី និង សុន សេន បានផ្លាស់ប្តូរចេញពី"មន្ទីរ១០០" ជិតព្រំដែនវៀតណាមក្នុងខេត្តរតនគិរី។ នៅពេលនោះ អៀង សារី បានធ្វើដំណើរទៅទីក្រុងប៉េកាំង ប្រទេសចិន។ នួន ជា បានឲ្យដឹងថា រតនគិរី គឺជាទីតាំងដ៏ល្អដើម្បីធ្វើបដិវត្តន៍ ព្រោះ"ខ្មាំងមិនអាចទៅដល់ទីនោះទេ"។ គាត់បានអះអាងថា

គាត់ធ្លាប់ធ្វើដំណើរទៅរតនគិរីម្ដងប៉ុណ្ណោះ ព្រោះផ្លូវដែលទៅនោះមានការលំបាកពេកដែលធ្វើឲ្យរថយន្ត មិនអាចបើកបរលើផ្លូវនោះបាន ហើយពេលធ្វើដំណើរទៅទីនោះត្រូវចំណាយពេលប្រហែលជាមួយខែ ដោយថ្មើរជើង ។ នួន ជា បានបញ្ជាក់ថា អង្គមេទ្ធញថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា មិនសូវធ្វើញឹកញាប់ទេ ដោយសារតែខេត្តរតនគិរីនៅឆ្ងាយពេក ។

នៅក្នុងឱកាស ព្រះរាជអាជ្ញាបានប្រាប់ទៅ នួន ជា វិញថា អង្គមេទ្ធញរបស់បក្សកុម្មុយនីស្តកម្ពុជាធ្វើជាប់រហូតពេញចុងទសវត្សរ៍៦០ ។ ដំបូងព្រះរាជអាជ្ញាបានសួរអំពីអង្គមេទ្ធញរបស់បក្សក្នុង ឆ្នាំ១៩៦៤ ដែលធ្វើឡើងជាច្រើនសប្ដាហ៍នៅក្នុងព្រៃនៅភូមិភាគឥសាន្តប្រទេសកម្ពុជានេះបើតាមការរៀបរាប់នៅក្នុងសៀវភៅរបស់ ខៀវ សំផន ។ នួន ជា បានឆ្លើយថា គាត់ «នឹកមិនឃើញ» ទេ អំពីកិច្ចប្រជុំរបស់គណៈមជ្ឈិមក្នុងឆ្នាំ១៩៦៥ កាលនោះបក្សបានប្តូរពីបដិវត្តន៍ហិង្សា មកជាបដិវត្តន៍សន្តិវិធីវិញ ដែលកំណត់ថា «ជារឿងចាំបាច់បំផុត» ។

ទាក់ទងទៅនឹងកិច្ចប្រជុំមជ្ឈិមក្នុងឆ្នាំ១៩៦៦ កាលនោះភូមិភាគទាំងអស់កំណត់យកផែនការដើម្បី «តស៊ូប្រដាប់អាវុធ» នួន ជា បាននិយាយថា ក្នុងឆ្នាំ១៩៦៦ «ស្ថានភាពមានភាពតានតឹងខ្លាំងណាស់» ដូច្នេះគាត់បានចូលរួមកិច្ចប្រជុំមួយដែលបានសម្រេចថា បក្សត្រូវ «បញ្ចូល» ការតស៊ូដោយអាវុធជាមួយនឹងការតស៊ូនយោបាយ ។ នួន ជា មិនចាំទេថា នេះជាកិច្ចប្រជុំមជ្ឈិមបក្សឬយ៉ាងណាទេ ព្រោះកាលនោះ «មានកិច្ចប្រជុំច្រើនណាស់» ។

នៅពេលសួរអំពីទីតាំងនិងកាលបរិច្ឆេទរបស់កិច្ចប្រជុំផ្សេងៗទៀត នួន ជា បានបញ្ជាក់ថា គាត់មិនចាំពីទីកន្លែងដែលកិច្ចប្រជុំនីមួយៗធ្វើឡើងទេ ព្រោះពេលនោះជាពេលវឹកវរយ៉ាងខ្លាំង ហើយមេដឹកនាំទាំងអស់ ត្រូវតែផ្លាស់ប្ដូរទីតាំងជាញឹកញាប់ដោយសារតែការទម្លាក់គ្រាប់បែកបេ-៥២របស់អាមេរិក ។ នួន ជា ក៏មិនចាំដែរថា អៀង សារី ត្រូវបានតែងតាំងជាលេខាភូមិភាគឥសាន្តតាំងពីពេលណានោះទេ ។ គាត់បានបញ្ជាក់ទៀតថា នៅពេលនោះថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកជាពីរ ហើយគាត់ផ្ទាល់ទទួលបន្ទុកមួយផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា ។ នៅពេលនោះ មិនទាន់មានការបែងចែកភូមិភាគច្បាស់លាស់ទេ ព្រោះតំបន់នីមួយៗមានស្ថានភាពប្រយុទ្ធនឹងកាលៈទេសៈផ្សេងៗគ្នា ។ ក្រោយមក នួន ជា បានអះអាងថា គាត់មិនបានគ្រប់គ្រងបក្សទូទៅទេ ព្រោះភូមិភាគនីមួយៗត្រូវមើលការខុសត្រូវតាមមូលដ្ឋានដោយខ្លួនឯង ។

ចំពោះសំណួរអំពីការគេចខ្លួនរបស់ ខៀវ សំផន ក្នុងឆ្នាំ១៩៦៧ នួន ជា បានឆ្លើយថា គាត់មិនដឹងអ្វីទាំងអស់ទាក់ទងទៅនឹងបញ្ហា ហ៊ូ នឹម, ហ៊ូ យន់ និង ខៀវ សំផន ក្នុងការរត់គេចខ្លួនពីទីក្រុងភ្នំពេញនោះទៅជនបទនោះ ។ នួន ជា នឹកមិនឃើញទេ អំពីកិច្ចប្រជុំនៅទីក្រុងភ្នំពេញដែលបក្ស

កុម្មុយនីស្តកម្ពុជា សម្រេចមកចាប់យកការតស៊ូដោយអាវុធដើម្បីសម្រេចបាននូវបដិវត្តន៍សង្គមនិយមវិញនោះ ។

## ហេតុការណ៍ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០

ព្រះរាជអាជ្ញាបានបន្តប្រធានបទទៅរកព្រឹត្តិការណ៍ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០វិញ ដោយបានចោទជាសំណួរអំពីរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ ។ ពេលនោះ នួន ជា បានបដិសេធថា គាត់មិនមានឈ្មោះនៅក្នុងស្ថាប័នទាំងពីរនោះទេ ហើយថា ស្ថានប័នទាំងពីរគឺផ្សេងគ្នាពីបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់ក៏មិនដឹងពីកិច្ចការផ្ទៃក្នុងរបស់ស្ថានប័ននេះដែរ ។ គាត់បានបញ្ជាក់ទៀតថា គាត់មិនដឹងអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងស្ថាប័នទាំងពីរនេះទេ ហើយមិនដឹងអំពីកិច្ចការទូទៅដែរ ។

នៅពេលសួរ អំពីទីបញ្ជាការដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជានៅខេត្តរតនគិរីត្រូវបានប្តូរមកជិតស៊ឹងជីនិតវិញ ។ នួន ជា បានបញ្ជាក់ថា គាត់មិនចាំទេ ដោយសារតែគាត់បានផ្លាស់ប្តូរទីលំនៅរបស់ខ្លួនជាប្រចាំអំឡុងពេលនោះ ដូច្នេះគាត់មិនដឹងថា គាត់ទៅទីណាខ្លះទេ ។ នួន ជា បានបញ្ជាក់ទៀតថា គាត់បានធ្វើដំណើរទៅគ្រប់ភូមិភាគទាំងអស់ដើម្បី«អប់រំ»រួមទាំងនៅម្តុំជិតស៊ឹងជីនិតផង ហើយក៏បានបដិសេធផងដែរថា «សាលានយោបាយ»របស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតឡើងដើមទសវត្សរ៍៧០ ។ គាត់បានបញ្ជាក់ទៀតថា គាត់មិនដឹងថា ខៀវ សំផន នៅទីណាទេក្នុងអំឡុងពីឆ្នាំ១៩៧០ដល់១៩៧៥ ព្រោះនេះជា«កិច្ចការសម្ងាត់» ។

បន្ទាប់មក នួន ជា បានបញ្ជាក់ទៀតថា គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជាមិនបានជួបប្រជុំគ្នាទៀងទាត់ទេ តែកិច្ចប្រជុំធ្វើរៀបចំឡើង«តាមសភាពការណ៍ជាក់ស្តែង»អំឡុងពេលនោះ ។ គាត់បានបន្តទៀតថា មានការប្រជុំ«ទៀតទាត់» និងការប្រជុំ«វិសាមញ្ញ» តែបក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈបត់បែនច្រើនតាម«ស្ថានភាពនយោបាយ» ។ ចំណែកឯគណៈមជ្ឈិមវិញ នួន ជា បានបញ្ជាក់ថា ក្រុមនេះធ្វើការជាមួយគ្នារាល់ថ្ងៃ ហើយជួបគ្នាតែពេលត្រូវជួបប៉ុណ្ណោះ ។ ចំពោះសំណួរដែលទាក់ទងទៅនឹងទីតាំងនៃការប្រជុំគណៈអចិន្ត្រៃយ៍ នួន ជា មើលទៅហាក់បីដូចជាមានការធុញថប់ ដោយបញ្ជាក់ថា គាត់បានឆ្លើយច្រើនដងហើយថា កិច្ចប្រជុំប្តូរទីតាំងជាប់រហូតព្រោះកាលនោះមានការ«វាយឆ្មក់ជាច្រើនដង» ។

នួន ជា បានផ្តល់សក្ខីកម្មទៀតថា យុទ្ធសាស្ត្រយោធាគឺអាស្រ័យទៅលើភូមិភាគនីមួយ ៗផ្ទាល់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ដោយយោងតាមស្ថានភាពជាក់ស្តែង ។ គាត់បានបញ្ជាក់ទៀតថា កាលនោះមាន«វគ្គសិក្សា»រួមដោយមានការចូលរួមពីយោធាមកពីភូមិភាគច្រើន តែ នួន ជា មិនដឹងអំពី

ការបង្កើតគណៈកម្មការសមរភូមិរួមទៀតដែលទទួលខុសត្រូវខាងយុទ្ធសាស្ត្រជាតិទាំងមូលទេ ។ នៅពេលសួរអំពីថា តើ អៀង សារី ត្រលប់មកពីប្រទេសចិនទេក្នុងរវាងឆ្នាំ១៩៧១ដល់១៩៧៦ ដើម្បីប្រជុំគណៈអចិន្ត្រៃយ៍ នួន ជា បានឆ្លើយថា គាត់មិនចាំទេ ។

## សមាជបក្សលើកទីបីក្នុងឆ្នាំ១៩៧១

នួន ជា បានធ្វើការអះអាងថា គាត់បានចូលរួមក្នុងសមាជបក្សលើកទីបីក្នុងឆ្នាំ១៩៧១ តែគាត់មិនចាំទីតាំងរបស់សមាជនោះទេ ហើយចំនួនអ្នកចូលរួមសមាជប៉ុន្មាននាក់ក៏មិនចាំដែរ ។ នៅពេលសួរថា តើសមាជនោះនិយាយពីអ្វី? នួន ជា បានបង្អក់មួយសន្ទុះ ដោយមើលទៅអ្វីដែលគាត់បានសរសេរនៅក្នុងសៀវភៅតូចជាមុនសិន មុននឹងឆ្លើយ ដោយបានឆ្លើយតបថា គាត់ក៏មិនចាំដែរ ។ ចំពោះកិច្ចប្រជុំឆ្នាំ ១៩៧២ សម្រេចថា ត្រូវបិទផ្សារនៅក្នុង«តំបន់រំដោះ»នេះគឺជាការសម្រេចផ្នែករដ្ឋបាល ដែលហួសពីដែនសមត្ថភាពរបស់គាត់ដែលមានតួនាទីជាអ្នកអប់រំ ។

នៅពេលដែលលើកពីពាក្យដែលស្រង់ចេញពីទស្សនាវដ្ដីទង់បដិវត្តន៍ បោះពុម្ពក្នុងឆ្នាំ១៩៧៦ ដែលបានសម្រេចឲ្យមានការបិទផ្សារក្នុងឆ្នាំ១៩៧២នោះ នួន ជា បានបញ្ជាក់ថា គាត់មិនចាំហេតុការណ៍នេះទេ តែគាត់គិតថា ផ្សារមិនទាន់បិទទេក្នុងឆ្នាំ១៩៧២ ។ គាត់បាននិយាយទៀតថា ភូមិភាគនីមួយៗសម្រេចដោយខ្លួនឯងរៀងៗខ្លួន ។

ទន្ទឹមនឹងនោះ នួន ជា នៅតែជម្ទះទាមទារកឯកសារដើមរបស់ទស្សនាវដ្ដីទង់បដិវត្តន៍ដដែល នៅពេលដែលព្រះរាជអាជ្ញាសួរអំពីសេចក្ដីថ្លែងរបស់គាត់ ។ ជាថ្មីម្ដងទៀត លោកចៅក្រម និល ណុន បានប្រានចោលសំណើរបស់ នួន ជា ព្រមទាំងបានរំឭកទៅ នួន ជា ម្ដងទៀតថា អង្គជំនុំជម្រះមិននិយាយអំពីឯកសារដើមនៅពេលនេះទេ គឺនិយាយតែពីអ្វីដែលបានរៀបរាប់នៅក្នុងសៀវភៅនោះប៉ុណ្ណោះ ។

## បញ្ហាក្នុងការបកប្រែ និងបច្ចេកទេស

ក្រោយមក អង្គជំនុំជម្រះមានបញ្ហាបច្ចេកទេសមួយចំនួនដែលជាហេតុធ្វើឲ្យព្រះរាជអាជ្ញាមិនអាចបញ្ចាំងឯកសារនៅលើអេក្រង់បាន ។ បញ្ហាផ្សេងទៀតនោះគឺថា មានបញ្ហាក្នុងការបកប្រែខ្លះនៅពេលដែលព្រះរាជអាជ្ញាអានពាក្យនៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍ជាភាសាអង់គ្លេសដូចជាពាក្យ «seize the people» បែរជាអ្នកបកប្រែបកផ្សេងទៅវិញដែលធ្វើឲ្យមានការភាន់ច្រឡំ ។ ក្រោយមក ពាក្យនោះត្រូវបានអានជំនួសដោយព្រះរាជអាជ្ញាខ្មែរ ។

តែការអានជាភាសាខ្មែរមិនឃើញមានពាក្យ «seize the people» នោះទេ បន្ទាប់មកមានការផ្ទៀងផ្ទាត់គ្នាឡើងវិញជាភាសាអង់គ្លេស ។ ព្រះរាជអាជ្ញាជាតិអានជាភាសាខ្មែរដែលមានន័យថា ជា «control the people» ឬ «conquer the people» ទៅវិញ ។

ការភាន់ច្រឡំនេះ រឹតតែធ្វើឲ្យ នួន ជា ចង់ឃើញឯកសារដើមកាន់តែខ្លាំងឡើង ហើយគាត់បាននិយាយថា «ឥឡូវនេះលោកឃើញហើយនូវអ្វីដែលខ្ញុំចង់ឃើញពីឯកសារដើមនោះ» ព្រោះឯកសារថតចម្លងមិនអាចទទួលយកបានទេ ។

## នួន ជា និង អៀង សារី ចង់ទៅតាមដានដំណើរការក្នុងបន្ទប់សម្រាកវិញនៅពេលរសៀល

មុននឹងសម្រាកទទួលទានអាហារថ្ងៃត្រង់ នួន ជា បានស្នើសុំទៅអង្គជំនុំជម្រះ អនុញ្ញាតឲ្យខ្លួនតាមដានដំណើរការសវនាការពីក្នុងបន្ទប់រង់ចាំវិញនៅរសៀលនេះ ។ ស្របពេលជាមួយគ្នានោះ មេធាវីរបស់ អៀង សារី បានក្រោកឡើងដោយបានស្នើស្រដៀងគ្នាដែរ សុំអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនទៅសម្រាក ។ ពេលនោះ អង្គជំនុំជម្រះសាលាដំបូងសម្រេចយល់ព្រមទទួលសំណើរបស់ជនជាប់ចោទទាំងពីរ ។ មានការសង្កេតឃើញថា នួន ជា និង អៀង សារី នឹងបង្ហាញខ្លួននៅចំពោះមុខអង្គសវនាការតែពេលព្រឹកប៉ុណ្ណោះសម្រាប់ថ្ងៃទៅមុខទៀត ។ ចំណែកឯ ខៀវ សំផន បានប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ខ្លួន ។

នៅពេលរសៀល ជានាទីរបស់ជនជាប់ចោទ ខៀវ សំផន នឹងត្រូវមកធ្វើសក្ខីកម្មតាមកម្មវិធី ។ មុននឹងនាំខ្លួន ខៀវ សំផន ទៅកាន់ទីក្រចកសេះ មានការមិនច្បាស់លាស់ទេថា តើ ខៀវ សំផន នឹងឡើងនិយាយឬអត់ ។ ចៅក្រម និល ណុន បានបញ្ជាក់ថា ខៀវ សំផន មិនមានភាពច្បាស់លាស់ទេថា តើគាត់ត្រូវផ្តល់សក្ខីកម្ម ឬក៏ត្រូវរក្សាសិទ្ធនៅស្ងៀមនោះ ។ មេធាវីជាតិរបស់ ខៀវ សំផន បានជូនដំណឹងទៅអង្គជំនុំជម្រះថា ខៀវ សំផន នឹងមិនឆ្លើយសំនួរណាមួយអំពីកំណរកំណើតរបស់ចលនាខ្មែរក្រហមទេ ។

នៅពេលចៅក្រម ឡាវ៉ែរញ បានសួរ ខៀវ សំផន អំពីតំណែងរបស់គាត់ តែ ខៀវ សំផន បានឆ្លើយថា គាត់នឹងមិនឆ្លើយសំនួរនេះទេ ។ ខៀវ សំផន បានបន្តទៀតថា គាត់បាននិយាយពីប្រធានបទនេះរួចហើយកាលពីឆ្នាំមុន ។ ក្នុងន័យដឹងច្បាស់ពីនីតិក្រម ខៀវ សំផន បាននិយាយពីកម្មវិធីរបស់អង្គជំនុំជម្រះ ដោយគូសបញ្ជាក់ថា សំនួរដែលត្រូវចោទសួរនៅពេលនេះគឺអំពីកំណរកំណើតរបស់ចលនាខ្មែរក្រហម ។ ខៀវ សំផន ក្រោកឈរនៅក្នុងទីក្រចកសេះដោយកាន់ក្រដាស់មួយសន្លឹកផង បញ្ជាក់ថា គាត់នឹងរៀបរាប់ពីការបែងចែករដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា តែគាត់ជឿថាពេលនេះមិនមែនជាពេលដែលត្រូវពិភាក្សាអំពីរឿងនេះទេ ។

### នួន ជា ងុយដេក

ក្នុងអំឡុងពេលនៃការជជែកគ្នានេះ មេធាវីប្រឹក្សារបស់ នួន ជា បានក្រោកឈររួចជម្រាបទៅអង្គជំនុំជម្រះថា នួន ជា មានការនឿយហត់តាំងពីព្រឹកមកហើយ ពេលនេះគាត់កំពុងតែដេកលក់នៅក្នុងបន្ទប់រង់ចាំ ចំណែកប្រព័ន្ធសម្លេងក៏បានបិទដែរ ។ មេធាវីបានបញ្ជាក់ថា គាត់បានប្រគល់ជូនឯកសារជាលាយលក្ខណ៍អក្សរទៅ នួន ជា ហើយក្នុងការដែលគាត់សុំសិទ្ធមិននៅក្នុងបន្ទប់សវនាការ តែគាត់មិនហ៊ានឲ្យ នួន ជា ធ្វើអីទៀតទេព្រោះគាត់មិនចង់ឲ្យ នួន ជា ភ្ញាក់ ។ ចំនុចនេះធ្វើឲ្យមានសំណួរមួយចំនួនពីចៅក្រម ឡាវើញ តែហាក់បីដូចជាមិនមានដំណោះស្រាយអ្វីទេ ព្រោះអង្គសវនាការផ្តោតទៅលើបញ្ហា ខៀវ សំផន មួយប៉ុណ្ណោះថា តើគាត់អាចធ្វើសក្ខីកម្មបានដែរឬអត់? បញ្ហានេះនឹងត្រូវយកមកនិយាយនៅពេលក្រោយទៀត ចំពោះ នួន ជា ដែលកំពុងតែដេកលក់ស្តាប់មិនឮទេ ព្រោះប្រព័ន្ធសម្លេងបានបិទដែរ ដូច្នេះជនជាប់ចោទរូបនេះមិនអាចតាមដានដំណើរការសវនាការទេ ។

### អង្គជំនុំជម្រះព្យាយាមឈ្វេចយកសក្ខីកម្មរបស់ ខៀវ សំផន

បង្វែរមករកបញ្ហា ខៀវ សំផន វិញ ចៅក្រម ឡាវើញ បានពន្យល់ថា សំណួរថ្ងៃនេះនឹងសួរអំពីសេចក្តីថ្លែងការណ៍របស់គាត់អំពីប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជាដែលគាត់ធ្លាប់និយាយរួចហើយ ។ ចៅក្រម ឡាវើញ បាននិយាយថា អង្គជំនុំជម្រះអាចសួរគាត់អំពីឯកសារជាក់លាក់ណាមួយ ហើយគាត់ឮពីគំនិតរបស់ ខៀវ សំផន ទាក់ទងទៅនឹងឯកសារនោះ ។ ចៅក្រម ឡាវើញ បានរំឭកទៅ ខៀវ សំផន ទៀតថា នេះគឺជាឱកាសមួយដែលគាត់អាចបញ្ជាក់ពីគំនិតរបស់ខ្លួន ។

ក្រោយពីទទួលការណែនាំពីអង្គជំនុំជម្រះ និងបានចំណាយពេលពិគ្រោះជាមួយមេធាវីរបស់គាត់ ខៀវ សំផន បានបញ្ជាក់ថា កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ គាត់បានបញ្ជាក់ពីជំហររបស់គាត់ទាក់ទងនឹងប្រធានបទនេះ ហើយបានបន្តទៀតថា គាត់មិនមានអ្វីត្រូវបន្ថែមទៀតទេ ។

ដោយសារតែមានការភាន់ច្រឡំ ចៅក្រម ឡាវើញ បានពន្យល់ទៅកាន់ ខៀវ សំផន ថា នៅក្នុងសវនាការនេះ អង្គជំនុំជម្រះអាចបង្ហាញឯកសារពិតប្រាកណាក៏បាន បើសិនជាអង្គជំនុំជម្រះយល់ថា ឯកសារនោះមានការពាក់ព័ន្ធ និងបញ្ជាក់ទៀតថា ខៀវ សំផន អាចនឹងប្រត្តិកម្មចំពោះឯកសារនោះ ហើយ គាត់ក៏អាចផ្តល់យោបល់លើឯកសារនោះបានដែរ ។ ចៅក្រម ឡាវើញ បានបន្តថា ឯកសារដែលជាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ជាពិសេសសរសេរដោយ ខៀវ សំផន ផ្ទាល់ ពេលនេះ ចៅក្រមចង់បានយោបល់ពី ខៀវ សំផន ។

ក្រោយពីពន្យល់រួចហើយ អង្គជំនុំជម្រះបានផ្តល់ពេលវេលាខ្លះទៅមេធាវីរបស់ ខៀវ សំផន ដើម្បីពិគ្រោះជាមួយកូនក្តីរបស់ខ្លួនទាក់ទងនឹងបញ្ហានេះ ។ ក្រោយពីសម្រាករួចមក មេធាវីរបស់ ខៀវ

សំផន បានជូនដំណឹងទៅអង្គជំនុំជម្រះថា កូនក្តីរបស់ខ្លួនសុំសិទ្ធិនៅស្ងៀមដោយមិនឆ្លើយសំនួរអ្វីទាំងអស់ ។

ចៅក្រម ឡាវើញ បានពិភាក្សាអំពីឯកសារជាក់លាក់មួយចំនួនដែលអង្គជំនុំជម្រះចង់ពិភាក្សាជាមួយ ខៀវ សំផន។ ដំបូង ចៅក្រម ឡាវើញ បានអានឯកសារមួយដែលក្នុងនោះ ខៀវ សំផន ត្រូវគេដកស្រង់ថា ពេលដែលគាត់កំពុងលាក់ខ្លួនកាលពីដើមទសវត្សរ៍៧០ គាត់បានធ្វើដំណើរជាមួយ តាម៉ុក ហើយបានជួបជាមួយ ប៉ុល ពត នៅជនបទ ហើយចាប់តាំងពីជំនួបនោះមក ទើបគាត់ដឹងថា ប៉ុល ពត គឺជាលេខាបក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងឯកសារនោះ ខៀវ សំផន បានបញ្ជាក់ថា ប៉ុល ពត បានហៅគាត់ថា "កូនប្រុសរបស់វណ្ណៈសក្តិភូមិទន់ខ្សោយ" នៅពេលដែល ខៀវ សំផន ប្រកាសខ្លួនឯងជាបញ្ញាវន្ត ពាក្យនោះធ្វើឲ្យ ខៀវ សំផន ភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះគាត់កើតមកជាគ្រួសារក្រីក្រ ។

ចៅក្រម ឡាវើញ បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពេញចិត្តរាល់ការបកស្រាយរបស់ ខៀវ សំផន ចំពោះអត្ថន័យពាក្យ"កូនប្រុសរបស់វណ្ណៈសក្តិភូមិទន់ខ្សោយ" ។ ខៀវ សំផន បានបញ្ជាក់ថា ឃ្លានេះ គឺជាពាក្យដែលគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដាក់ឲ្យគាត់ ពេលដែលគាត់ត្រូវបានបញ្ចូលនៅក្នុងបក្ស ។ ជាពិសេស គាត់ត្រូវបាន"អនុគ្រោះ" ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាឲ្យក្លាយជាសមាជិកបក្ស តែមិនមែនជាសមាជិកជាក់លាក់ទេព្រោះគាត់មានទស្សនៈឯករាជ្យ ។ ខៀវ សំផន បានបញ្ជាក់ទៀតថា គាត់សង្ឃឹមថា ឯកសារនេះអាចនិងមានប្រយោជន៍សម្រាប់យកមកប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះ ដើម្បីសរបញ្ជាក់ឲ្យឃើញថាតើគាត់ជា"មេដឹកនាំជាន់ខ្ពស់"របស់បក្សឬយ៉ាងណា ។ នៅពេលដែលចៅក្រម ឡាវើញ ជម្រុញ ខៀវ សំផន បន្តរទៀតឲ្យបកស្រាយពីអត្ថន័យនៃពាក្យ "កូនប្រុសរបស់វណ្ណៈសក្តិភូមិទន់ខ្សោយ" មេធាវីការពារក្តីរបស់ ខៀវ សំផន បានក្រោយឡើង និងធ្វើការជំទាស់ដោយបញ្ជាក់ថា មេធាវីការពារក្តីបានបញ្ជាក់ច្បាស់រួចហើយថា ខៀវ សំផន និងមិនឆ្លើយសំនួរអ្វីទាំងអស់ ។

ក្រោយពីលឺមេធាវីរបស់ ខៀវ សំផន និយាយដូច្នេះ ចៅក្រម ឡាវើញ បានបន្តពិភាក្សាអំពីសៀវភៅរបស់ ខៀវ សំផន ដែលឆ្លុះបញ្ចាំងពីប្រវត្តិសាស្រ្តកម្ពុជាថ្មីៗ ។ វិធីសាស្ត្ររបស់ចៅក្រមនៅតែមិនមានប្រសិទ្ធភាពដដែលក្នុងការបញ្ចុះបញ្ចូល ខៀវ សំផន ឲ្យឆ្លើយទៅនិងសំនួរ ហើយពេលនេះ ជនជាប់ចោទរូបនេះបានឆ្លើយថា គាត់គឺជាអ្នកនិពន្ធសៀវភៅនោះ តែគាត់បដិសេធមិនធ្វើការបកស្រាយទៅនិងសៀវភៅនោះទេ ។

នៅពេលចៅក្រម ឡាវើញ អានឃ្លាមួយនៅក្នុងសៀវភៅនោះ មេធាវីរបស់ ខៀវ សំផន បានក្រោកឈរឡើងម្តងទៀត ហើយស្នើឲ្យចៅក្រម ឡាវើញ បញ្ឈប់ការសួរសំនួរទៅ ខៀវ សំផន ទៀត ព្រោះគាត់បានរក្សាសិទ្ធនៅស្ងៀមរួចទៅហើយ ហើយថា បើសិនជាសួរសំនួរទៅកាន់កូនក្តីរបស់ខ្លួនបន្តទៀត នេះសរបញ្ជាក់ឲ្យឃើញថាជាការរំលោភសិទ្ធក្នុងការនៅស្ងៀមរបស់កូនក្តីរបស់ខ្លួន។

សំណើនេះត្រូវបានជំទាស់ ហើយចៅក្រម ឡាវ៉ើញ បានបន្តអានឃ្លាមួយផ្សេងទៀតដែលរៀបរាប់អំពីជម្លោះផ្ទៃក្នុងជាមួយរដ្ឋាភិបាលសម្តេច សីហនុ មុននិងការបោះឆ្នោតឆ្នាំ១៩៦៦។ ពេលនេះ ខៀវ សំផន នៅតែជំទាស់ដដែល ហើយគាត់បានឆ្លើយថា គាត់មិនចង់ផ្តល់យោបល់អ្វីទាំងអស់។

ចៅក្រមបានអានឃ្លាមួយទៀតដែលនិយាយអំពីហេតុការណ៍ពេលដែល ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ គេចខ្លួនពីភ្នំពេញ។ ចំណុចនេះធ្វើឲ្យមេធាវីការពារក្តីរបស់ ខៀវ សំផន ជំទាស់ម្តងទៀត ហើយមេធាវីបានបញ្ជាក់ថា បើសិនជានៅតែព្យាយាមឲ្យកូនក្តីរបស់គាត់"ផ្តល់យោបល់"បន្តទៀតនោះ នោះពិតជាមានន័យថា ជនជាប់ចោទមិនមាន"សិទ្ធពេញលេញ"ក្នុងការនៅស្ងៀមមិនឆ្លើយតបទេ។

ដោយសារតែនៅតែជជែកចុះឡើងៗពីបញ្ហានេះ ចៅក្រម និល ណុន បានស្នើរថា ចៅក្រម ឡាវើញ អាចបន្តសួរទៀតបានអំពីឯកសារដែលអង្គជំនុំជម្រះជឿថាកំពុងមានភាពមិនច្បាស់លាស់ ហើយចៅក្រម និល ណុន បានស្នើរថា មិនគួរស្នើរឲ្យ ខៀវ សំផន ផ្តល់យោបល់អ្វីមួយទេ។

## ឯកសាររបស់អង្គជំនុំជម្រះដាក់ចូលទៅក្នុងសំណុំឯកសារ ហើយនិងការបញ្ចប់កម្មវិធី

ចៅក្រម ឡាវ៉ើញ បានបន្តសួរទៅមុខបន្តិចទៀតព្រោះអង្គជំនុំជម្រះយល់ឃើញថា ឯកសារមួយចំនួននៅមានភាពមិនច្បាស់លាស់ ដូចជា ៖

- សៀវភៅដែលសរសេរដោយ ខៀវ សំផន
- ឯកសារមួយ អសនះរបស់កម្ពុជានៅអង្គការសហប្រជាជាតិ សរសេរដោយ ខៀវ សំផន តំណាងឲ្យរដ្ឋាភិបាលរួបរួមជាតិ និងចលនាបង្រួបបង្រួមជាតិកម្ពុជា
- ទស្សនាវដ្តីទង់បដិវត្តន៍មួយចំនួន
- អត្ថបទសារព័ត៌មានមួយចំនួនសរសេរដោយសារព័ត៌មានកម្ពុជា និង
- ពាក្យពេចថ្លែងសុន្ទរកថារបស់ ខៀវ សំផន

*ក្រោយមក ព្រះរាជអាជ្ញាបានស្នើរឲ្យមេធាវីការពារក្តីរបស់ ខៀវ សំផន បញ្ជាក់ឲ្យច្បាស់ម្តងទៀតថាតើ ខៀវ សំផន មានគម្រោងចង់ផ្តល់សក្ខីកម្ម ឬក៏ប្រើប្រាស់សិទ្ធនៅស្ងៀមនាអំឡុងពេលសវនាការថ្ងៃក្រោយទៀតពេលដែលសវនាការសាកសួរអំពីតួនាទីរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។*

*សំនួរនេះធ្វើឲ្យ ខៀវ សំផន ទៅពិគ្រោះជាមួយមេធាវីរបស់ខ្លួនមួយសន្ទុះ ក្រោយមក ជនជាប់ចោទ ខៀវ សំផន បានប្រាប់ទៅព្រះរាជអាជ្ញាថា គាត់សុំពេលគិតសិនថាតើគាត់និងផ្តល់សក្ខីកម្ម ឬអត់នាពេលក្រោយៗមកទៀត ។*

*ទីបញ្ចប់ ចៅក្រម និល ណុន បានបញ្ជាក់ថា “សវនាការនៅពេលរសៀលនេះហាក់បីដូចជាដំណើរការល្អប្រកបដោយប្រសិទ្ធភាពជាងការរំពឹងទុក” ហើយគាត់បានប្រកាសថា អង្គជំនុំជម្រះនិងបញ្ចប់នៅពេលនេះ ហើយនិងបន្តរទៀតនៅថ្ងៃចន្ទ ។ មុននិងប្រកាសសម្រាក ចៅក្រម និល ណុន បានជម្រាបទៅសាធារណជនទាំងអស់ថា ចៅក្រម ខាត់វ្រ៉ាយត៍ និងមិនមានវត្តមានទេ ហើយពេលដែលគាត់អវត្តមាន ចៅក្រមបម្រុងអន្តរជាតិជនជាតិអូទ្រីសឈ្មោះ ក្លូឌើ ហ្វេនហ្ស និងចូលមកជំនួស ។ ចៅក្រម និល ណុន បានបញ្ជាក់ថា អំឡុងពេលពេញមួយសប្តាហ៍ក្រោយ អង្គជំនុំជម្រះនិងនិយាយតែពីបញ្ហាភស្តុតាងប៉ុណ្ណោះ ។ ចៅក្រម និល ណុន បានប្រកាសបញ្ចប់កម្មវិធីសម្រាប់ថ្ងៃនេះ ហើយនៅថ្ងៃចន្ទ ទី១៦ ខែមករា អង្គជំនុំជម្រះនិងចាប់ផ្តើមនៅវេលាម៉ោង៩ៈ០០ព្រឹក ។*

**-ចប់-**